ការផ្សារភ្ជាប់

ថ្ងៃទី 29 ខែមេសា ឆ្នាំ 2022

មតិរបស់អគ្គនាយក

ជម្រាបសួរគ្រួសារ PPSD ហើយសូមស្វាគមន៍មកកាន់ការបោះពុម្ពចុងក្រោយបង្អស់នៃព្រឹត្តិបត្រព័ត៌មានប្រចាំពីរសប្តាហ៍របស់យើង! ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ខកខានមិនបានទទួលព្រឹត្តិបត្រព័ត៌មានទាំងនេះណាមួយនោះ អ្នកអាចស្វែងរកការបោះពុម្ពកន្លងមកនៅលើគេហទំព័រ PPSDជាភាសាជាច្រើន។

ផ្នែកសំខាន់នៃគម្រោងសកម្មភាពផ្លាស់ប្តូរសហគមន៍របស់យើងសម្រាប់សាលា Providence Schools គឺការបង្កើនភាគរយនៃថ្ងៃនៅក្នុងថ្នាក់រៀនដែលមានបុគ្គលិកពេញលេញរបស់យើងនៅដើមឆ្នាំសិក្សានីមួយៗ និងដោយមានហេតុផលសមរម្យ ក្នុងនាមជាអតីតគ្រូបង្រៀននៅ PPSD ជាជំនួយការនាយកសាលា និងជានាយកសាលា ខ្ញុំអាចប្រាប់អ្នកពីបទពិសោធន៍ថាអ្នកអប់រំនៅក្នុងសាលាដែលមានចំនួនបុគ្គលិកសមស្របមានប្រសិទ្ធភាពជាង។ ហើយចំណុចនោះជួយឱ្យសិស្សរបស់យើងឱ្យរីកចម្រើន។

ដូច្នេះ ខ្ញុំបានជំរុញក្រុមរបស់ខ្ញុំឱ្យចាត់យកវិធីសាស្ត្រយ៉ាងមឺងម៉ាត់លើការជ្រើសរើសបុគ្គលិកសម្រាប់ឆ្នាំសិក្សាបន្ទាប់។ យើងមានការលើកទឹកចិត្តថ្មីៗជាច្រើនដើម្បីផ្តល់ជូនបេក្ខជន ហើយយើងបានប្រកាសមុខតំណែងនៅថ្ងៃទី 7 ខែមីនា ដែលលឿនជាងធម្មតាមួយខែ។

ហើយរយៈពេលមួយខែពិតជាផ្តល់លទ្ធផលខុសប្លែកពីគ្នា! គិតត្រឹមថ្ងៃនេះ យើងបានជួលបុគ្គលិក 206 នាក់សម្រាប់មុខតំណែង PTU នៅឆ្នាំក្រោយរួចហើយ។ នេះជាការវិភាគលម្អិតនៃការជួលបុគ្គលិកទាំងនោះ៖

- អ្នកអប់រំមាន 102 នាក់ដែលបានជំនួសដំណែងចាស់
- ការជួលបុគ្គលិកពីខាងក្រៅ និងថ្មីសម្រាប់ PPSD មានចំនួន 53 នាក់។
- អ្នកអប់រំដែលផ្លាស់ទៅតួនាទីថ្មី ឬដែលត្រូវបានតម្លើងឋានៈមាន 47 នាក់។
- អ្នកជំនួសដែលនឹងចូលរួមជាមួយយើងពេញម៉ោងមាន 11 នាក់។

បច្ចុប្បន្នយើងក៏មានការផ្តល់ជូនការងារចំនួន 15 ផ្សេងទៀតសម្រាប់បេក្ខជនផងដែរ។ សរុបមក យើងនៅឆ្ងាយជាងកន្លែងដែលយើងនៅកាលពីឆ្នាំមុន ដោយសារឆ្នាំមុន នៅពេលនេះយើងសូម្បីតែមិនបានចាប់ផ្តើមដំណើរការនេះផង។

ខ្ញុំយល់ច្បាស់ថាយើងមិនបានបញ្ចប់នៅត្រឹមនេះទេ។ ការជួលបុគ្គលិកនៅតែជាបញ្ហាប្រឈមដែលយើងត្រូវតែដោះស្រាយ ហើយនឹងដោះស្រាយ។ ប៉ុន្តែយើងកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ឆ្ពោះទៅរកការធ្វើឱ្យប្រាកដថាអគាររបស់យើងពោរពេញទៅដោយអ្នកអប់រំដែលមានគុណភាពខ្ពស់ ដែលត្រៀមខ្លួនជាស្រេចដើម្បីជួយសិស្សរបស់យើងឱ្យទទួលបានជោគជ័យ។

វេជ្ជបណ្ឌិត
JAVIER MONTAÑEZ
អគ្គនាយក

បច្ចុប្បន្នភាពរបស់មណ្ឌលសិក្សា

កម្មវិធីសិក្សាក្នុងរដូវក្តៅ

ការចុះឈ្មោះសម្រាប់កម្មវិធីសិក្សាក្នុងរដូវក្តៅរបស់ PPSD បានបើកហើយ! កម្មវិធីសិក្សាក្នុងរដូវក្តៅគឺឥតគិតថ្លៃសម្រាប់សិស្ស PPSD ទាំងអស់។ នៅឆ្នាំនេះ កម្មវិធីដែលបានពង្រីកនឹងបន្ថែមពេលវេលាដំណើរការជាច្រើនម៉ោងបន្ថែមទៀតជារៀងរាល់ថ្ងៃសម្រាប់សិស្សបឋមសិក្សា។ ដើម្បីបន្តការបង្កើនការគាំទ្រដល់អ្នកសិក្សាពហុភាសា PPSD ក៏បានរៀបចំកែសម្រួលកម្មវិធីសិក្សាក្នុងរដូវក្តៅឆ្នាំ 2022 ទាំងអស់ឱ្យមានការរួមបញ្ចូលយ៉ាងពេញលេញសម្រាប់សិស្សពហុភាសា។ ថ្មីផងដែរនៅឆ្នាំនេះ សិស្សវិទ្យាល័យនឹងអាចចូលប្រើប្រាស់កម្មវិធីអប់រំផ្នែកបច្ចេកវិទ្យា និងការងារ (CTE) អំឡុងពេលនៃកម្មវិធីសិក្សាក្នុងរដូវក្តៅ។ ជាថ្មីម្តងទៀត កម្មវិធីសិក្សាក្នុងរដូវក្តៅនឹងរួមបញ្ចូលការបង្កើនល្បឿននៃការសិក្សារបស់សិស្សបន្ថែមពីលើការផ្តល់ជូននូវការស្តារឡើងវិញ។ ក៏មានឱកាសសម្រាប់អាហារពេលព្រឹក និងអាហារថ្ងៃត្រង់ដោយឥតគិតថ្លៃសម្រាប់សិស្សគ្រប់រូប។ ស្វែងយល់បន្ថែមអំពីកាលបរិច្ឆេទកម្មវិធី និងព័ត៌មានលម្អិតនៅទីនេះ។

សប្តាហ៍នៃការរំលឹកគុណគ្រូ

ថ្ងៃទី 2 ដល់ថ្ងៃទី 6 ខែឧសភា គឺជាសប្តាហ៍នៃការរំលឹកគុណគ្រូ! ត្រូវប្រាកដថាអ្នកចំណាយពេលដើម្បីថ្លែងអំណរគុណ និងទទួលស្គាល់អ្នកអប់រំដែលខិតខំប្រឹងប្រែង និងមានការប្តេជ្ញាចិត្តខ្ពស់របស់យើង។ ប៉ុន្មានឆ្នាំកន្លងមកនេះ មានការពិបាកខ្លាំងសម្រាប់យើងទាំងអស់គ្នា ប៉ុន្តែការបង្រៀនគឺជាវិជ្ជាជីវៈមួយដែលរងគ្រោះខ្លាំងបំផុតដោយសារជំងឺរាតត្បាត។ ឆ្លងកាត់រឿងរ៉ាវទាំងនេះ គ្រូបង្រៀន PPSD របស់យើងបន្តទាញយកការចូលរួមជាមួយសិស្សរបស់យើង និងជួយពួកគេឱ្យរីកចម្រើន។ នេះជាការណែនាំមួយចំនួនសម្រាប់វិធីដែលអ្នកអាចឱ្យគ្រូដឹងថាពួកគេត្រូវបានគេកោតសរសើរ៖

- ពាក់ពណ៌ក្រហមក្នុងទិវាគ្រូបង្រៀនជាតិ (ថ្ងៃទី 3 ខែឧសភា ឆ្នាំ 2022)
- ឱ្យសិស្សជាកូនរបស់អ្នកសរសេរសំបុត្រមួយច្បាប់ទៅកាន់គ្រូបច្ចុប្បន្ន ឬអតីតគ្រូណាម្នាក់
- ប្រសិនបើសិស្សជាកូនរបស់អ្នកជាកុមារវ័យក្មេង ឱ្យពួកគេគូររូបភាពសម្រាប់គ្រូរបស់ពួកគេ
- ទាក់ទងទៅកាន់អ្នកអប់រំម្នាក់ ដែលមានឥទ្ធិពលមកលើជីវិតរបស់អ្នកផ្ទាល់
- បរិច្ចាគសៀវភៅទៅឱ្យបណ្ណាល័យថ្នាក់រៀនរបស់គ្រូអ្នក
- ស្វែងយល់អំពីអាហារសម្រន់ដែលគ្រូរបស់អ្នកចូលចិត្តជាងគេ ហើយធ្វើឱ្យពួកគេភ្ញាក់ផ្អើលជាមួយអាហារសម្រន់នោះ
- ត្រូវមានភាពច្នៃប្រឌិត - មិនមានរបៀបខុសនៃការបង្ហាញអំពីអំណរគុណរបស់អ្នកនោះទេ!

សាលាដ៏ល្អបំផុតមួយថ្នាក់ជាតិ

សូមអបអរសាទរដល់បុគ្គលិក និងសិស្សានុសិស្សដ៏ឧស្សាហ៍ព្យាយាមនៅសាលា Classical High School ចំពោះការជាប់ឈ្មោះជាថ្មីម្តងទៀតជា សាលាវិទ្យាល័យសាធារណៈដ៏ល្អបំផុតមួយក្នុងចំណោមសាលាវិទ្យាល័យដ៏ល្អបំផុតនានាក្នុងប្រទេស ដោយរបាយការណ៍ U.S. News and World Report! វិទ្យាល័យ Classical ជាប់ចំណាត់ថ្នាក់ជាសាលាវិទ្យាល័យល្អបំផុតនៅរដ្ឋ Rhode Island និងជាប់លេខ 91 ពីក្នុងចំណោមសាលាជាង 18,000 សាលានៅទូទាំងប្រទេសទាំងមូល។ ការចាត់ចំណាត់ថ្នាក់នេះផ្អែកទៅលើការវាស់វែងទាំងនេះ៖ ភាពត្រៀមរួចរាល់សម្រាប់ចូលថ្នាក់មហាវិទ្យាល័យ ភាពទូលំទូលាយនៃកម្មវិធីសិក្សាសម្រាប់មហាវិទ្យាល័យ លទ្ធផលវាយតម្លៃរបស់រដ្ឋ ភាពស្ទាត់ជំនាញក្នុងជំនាញអំណាននិងគណិតវិទ្យា លទ្ធផលក្នុងមុខវិជ្ជាអំណាននិងគណិតវិទ្យា លទ្ធផលរបស់សិស្សដែលមិនសូវទទួលបានជំនួយ និងអត្រានៃការបញ្ចប់ការសិក្សា។

ការត្រលប់ទៅកាន់សាលាវិញទាំងសុខភាពល្អ

សាលា Providence Public Schools បន្តតាមដានករណីរបស់ COVID-19 យ៉ាងជិតដល់នៅទូទាំងមណ្ឌលសិក្សា។ ម៉ាស់បានក្លាយជាជម្រើសតាមចិត្តសម្រាប់សិស្សនិងបុគ្គលិកនៅដើមខែនេះ ហើយសិស្សទាំងអស់បានត្រលប់មកពីវិស្សមកាលខែមេសាវិញនៅថ្ងៃទី 25 ខែមេសា។ អំឡុងសប្តាហ៍នៃការត្រលប់មកវិញពីវិស្សមកាលនេះ PPSD បានបន្តមានករណីវិជ្ជមានជាមធ្យមចំនួនប្រហែល 10 ករណីក្នុងមួយថ្ងៃនៅទូទាំងមណ្ឌលសិក្សាទាំងមូលដែលមានសិស្សជាង 20,000 នាក់ – ជាអត្រាដូចគ្នា ដែលមណ្ឌលសិក្សាមានជាមធ្យមសម្រាប់ប៉ុន្មានសប្តាហ៍មកហើយមកដល់ពេលនេះ។ វត្តមានក្នុងអំឡុងសប្តាហ៍នៃការត្រលប់មកវិញពីពេលសម្រាកក្នុងខែមេសាក៏មានចំនួនច្រើនជាងវត្តមានជាមធ្យមក្នុងឆ្នាំសិក្សាទាំងមូលបន្តិចផងដែរ គិតមកដល់ពេលនេះ។

ការអបអរសាទរដល់សិស្សានុសិស្ស

សិស្សដ៏ឧស្សាហ៍ព្យាយាមនិងប្រកបដោយទេពកោសល្យរបស់យើងកំពុងតែធ្វើរឿងរ៉ាវដ៏អស្ចារ្យនានាជារៀងរាល់ថ្ងៃ! នេះគ្រាន់តែជាឧទាហរណ៍មួយចំនួនប៉ុណ្ណោះ។

ដំណើរផ្សងព្រេង JROTC

កម្មវិធី Hope High School JROTC បានចុះកម្មសិក្សានៅ បន្ទាយកងការពារជាតិផ្លូវអាកាសនៅ Quonset នាថ្ងៃព្រហស្បតិ៍ ទី 14 ខែមេសានេះ។ សិស្សមកពីកម្មវិធីបានទទួលបទពិសោធន៍នៃទិដ្ឋភាពផ្សេងៗរបស់យោធា ដោយរកឃើញឱកាសដើម្បីធ្វើតេស្តកម្លាំងរបស់ពួកគេ ប្រឈមនឹងការភ័យខ្លាចរបស់ពួកគេ និងចូលរួមក្នុងសកម្មភាពបង្កើតមិត្តភាពក្នុងក្រុម។ ក្នុងអំឡុងពេលថ្ងៃ សិស្សបានជិះក្នុងឧទ្ធម្ភាគចក្រ Black Hawk ចុះជញ្ជាំងកម្ពស់ 40 ហ្វីត និងបានសិក្សាអំពីឱកាសការងារនានា! សូមមើលវីដេអូអំពី JROTC នៅទីនេះ៖ https://youtu.be/6fj6KDwrQp4

សិស្សថ្នាក់មុនមត្តេយ្យសិក្សាបង្ហាញភាពលេចធ្លោ

សិស្សថ្នាក់មុនចូលមត្តេយ្យ និងគ្រួសាររបស់ពួកគេបានចូលរួមក្នុងរាត្រី Make and Take Night សម្រាប់ថ្នាក់មុនចូលមត្តេយ្យ នៅសាលាបឋមសិក្សាPleasant View Elementary School នៅថ្ងៃច័ន្ទ ទី 11 ខែមេសានេះ។ កម្មវិធីកុមារវ័យក្មេងក៏បានរៀបចំកម្មវិធីក្នុងមជ្ឈមណ្ឌលបើកចំហសម្រាប់ថ្នាក់មុនចូលមត្តេយ្យផងដែរនៅបឋមសិក្សាYoung Woods នៅថ្ងៃអង្គារ ទី 5 ខែមេសា ដោយផ្តល់ជូនសិស្សនូវឱកាសបង្ហាញថ្នាក់រៀននិងការងាររបស់ពួកគេដល់គ្រួសាររបស់ពួកគេ។ ស្វែងយល់បន្ថែមអំពីកម្មវិធីកុមារវ័យក្មេងរបស់យើងនៅទីនេះ។

ការប្រកួតកំណាព្យ TAKE THE MIC

បណ្ណារក្សវិទ្យាល័យ Providence Public School High School និងបណ្ណាល័យសហគមន៍របស់ក្រុង Providence បានរៀបចំកម្មវិធីTake the Mic ដែលជាការប្រកួតកំណាព្យសម្រាប់ក្មេងជំទង់នៅបណ្ណាល័យ Knight Memorial Library ក្នុងទីក្រុង Providence នៅថ្ងៃទីពុធ ទី 27 ខែមេសា។ គ្រូបង្រៀន និងសិស្សបានចែករំលែកកំណាព្យរបស់ពួកគេ។ ពួកគេបានបង្ហាញថាពាក្យមានទៅដោយអំណាច!

បុគ្គលិកលេចធ្លោ

មកស្គាល់បុគ្គលិកឆ្នើមដែលធ្វើការជាមួយកូនរបស់យើងរៀងរាល់ថ្ងៃ!

Kyisha "លោកស្រី Kyi" Threats

គ្រូអភិវឌ្ឍភាសាអង់គ្លេសថ្នាក់ទី 7 និងទី 8
ប្រធានគ្រូមុខវិជ្ជាភាពជោគជ័យ 101 និង MLL ក្នុងថ្នាក់ទី 6
មានទីតាំងនៅក្នុង៖ អនុវិទ្យាល័យ DelSesto Middle School
បានចូលរួមជាមួយ PPSD ក្នុងឆ្នាំ៖ 1995

តើអ្នកនឹងរៀបរាប់ការងាររបស់អ្នកដល់មនុស្ស ដែលមិនធ្វើការក្នុងវិស័យអប់រំយ៉ាងដូចម្តេចដែរ?
ពេលខ្ញុំអង្គុយជាមួយអ្នកដទៃ ហើយពួកគេសួរខ្ញុំអំពីការលំបាកក្នុងនាមជាគ្រូបង្រៀន ខ្ញុំរំលឹកដល់ពួកគេថា កុមារទាំងនេះគឺជាផ្នែកនៃសហគមន៍របស់ខ្ញុំ ហើយក៏ជាសហគមន៍របស់យើង។ នោះហើយជាមូលហេតុ ដែលខ្ញុំស្រលាញ់អ្វីដែលខ្ញុំធ្វើ និងស្រលាញ់ការឈរនៅមុខថ្នាក់រៀនជារៀងរាល់ថ្ងៃ សូម្បីតែមានការលំបាកនានាក៏ដោយ។ ខ្ញុំតែងតែចែងថា "មូលហេតុ" របស់ខ្ញុំ ដោយមូលហេតុនោះគឺជាសិស្សរបស់ខ្ញុំ។ ពួកគេក៏មានការលំបាកដូចមនុស្សពេញវ័យ ហើយពួកគេត្រូវការបុគ្គលជាគំរូ និងមនុស្សដែលយកចិត្តទុកដាក់ចំពោះពួកគេនៅក្នុងថ្នាក់រៀន។ សូម្បីតែខ្ញុំបានបង្រៀនសិស្សតែម្នាក់ ក៏ខ្ញុំដឹងថាខ្ញុំបានធ្វើការងាររបស់ខ្ញុំហើយ។

> ការអប់រំគឺជាគន្លឹះ៖
> ពេលដែលអ្នកមានវាហើយ គ្មាននរណាម្នាក់
> អាចយកវាចេញពីអ្នកបាននោះទេ។

តើអ្វីទៅជាផ្នែកដ៏ល្អបំផុតក្នុងការងាររបស់អ្នក?
នោះគឺជាកុមារ។ ជាការគួរឱ្យពេញចិត្តណាស់ព្រោះថា ខ្ញុំធ្លាប់បានស្ថិតក្នុងស្ថានភាពមួយចំនួនដែលសិស្សរបស់ខ្ញុំកំពុងស្ថិតនៅក្នុងនាពេលឥឡូវ។ ខ្ញុំគឺជាផលិតផលរបស់ PPSD ទាំងកំណើតនិងការចិញ្ចឹមបីបាច់។ ខ្ញុំឱ្យពួកគេដឹងថា ខ្ញុំនៅទីនេះថ្ងៃនេះ ព្រោះខ្ញុំបានតស៊ូឆ្លងកាត់រឿងស្រដៀងគ្នា ដែលពួកគេប្រហែលជាកំពុងតែឆ្លងកាត់។ ការធ្វើដូច្នោះជួយយើងឱ្យនិយាយគ្នា ហើយខ្ញុំអាចណែនាំពួកគេឱ្យទៅរកសកម្មភាព ឬធនធានដែលពួកគេត្រូវការ។ រឿងដែលខ្ញុំចូលចិត្តប្រាប់សិស្សរបស់ខ្ញុំជាងគេគឺថា ការអប់រំគឺជាគន្លឹះ – ពេលដែលអ្នកទទួលបានវាហើយ គ្មាននរណាម្នាក់អាចយកវាចេញពីអ្នកបានទេ។

តើអ្នកមានបំណងចង់ឱ្យមនុស្សកាន់តែច្រើនដឹងអ្វីទៅអំពីការងាររបស់អ្នក ឬអំពី PPSD ជារួម?
ខ្ញុំនឹងប្រាប់មនុស្សម្នាថា កុំជឿគ្រប់យ៉ាងដែលអ្នកស្តាប់លឺតាមទូរទស្សន៍។ ចូរមកកាន់សាលារៀន ហើយមកស្គាល់កុមារ។ យើងមានសិស្សដ៏អស្ចារ្យ និងគ្រូដ៏អស្ចារ្យនៅ PPSD ។ ភាពអវិជ្ជមានគឺជារឿងគួរឱ្យសោកស្តាយណាស់។ ខ្ញុំប្រាថ្នាចង់ឱ្យមនុស្សនៅក្នុងសហគមន៍យល់ថា ពេលវេលាពីមួយថ្ងៃទៅមួយថ្ងៃនៅក្នុងសាលារៀនវាយ៉ាងណាដែរ និងរបៀបដែលថា ការនៅក្នុងថ្នាក់រៀននៅក្នុងសាលាគួរឱ្យពេញចិត្តប៉ុនណា។

តើអ្វីទៅជាឧបសគ្គដែលសិស្សរបស់អ្នកបានជំនះក្នុងឆ្នាំនេះ ដែលអ្នកមានមោទនភាពទៅលើ?
ខ្ញុំនឹងនិយាយថា របៀបដែលពួកគេប្រាស្រ័យទាក់ទងជាមួយគ្នា។ មានការលំបាកយ៉ាងពិតប្រាកដ បន្ទាប់ពីការសិក្សាពីចម្ងាយ និងជាមួយនឹងម៉ាស់។ ឥឡូវនេះខ្ញុំឃើញពួកគេបង្កើតជាក្រុម ដែលពួកគេកំពុងធ្វើការជាមួយគ្នា លេងជាមួយគ្នា និយាយជាមួយគ្នា និងមានភាពរីករាយក្នុងសភាពជាកូនក្មេង។ ហើយ ពេលពួកគេប្រើកាន់យកផ្នត់គំនិតនោះ ពួកគេអាចទាក់ទងជាមួយគ្រូបានយ៉ាងងាយស្រួល ហើយយើងអាចនិយាយអំពីអ្វីមួយ ដែលជារឿងសំខាន់ខ្លាំង។

ដំណឹងល្អ៖ PPSD នៅក្នុងសារព័ត៌មាន

- សិស្សានុសិស្សនៃសាលាក្នុងទីក្រុង Providence កំពុងវិវឌ្ឍទៅជាអនាគតនិយោជក និងទទួលបានប្រាក់ឈ្នួលក្នុងការធ្វើដូច្នោះ
  សារព័ត៌មាន Boston Globe ចុះថ្ងៃទី 11 ខែមេសា ឆ្នាំ 2022
- អភិបាលក្រុង Elorza ដៃគូសហគមន៍ និងមន្ត្រីរបស់ទីក្រុងប្រកាសផ្សាយនូវឱកាសនៃកម្មវិធីរដូវក្តៅនៃការងារ លេង និងសិក្សារបស់ PVD ប្រចាំឆ្នាំ 2022
  សារព័ត៌មាន Public Now ចុះថ្ងៃទី 19 ខែមេសា ឆ្នាំ 2022
- ក្រុមប្រឹក្សាភិបាលនៃសាលា Providence អំពាវនាវឱ្យមានការគាំទ្រដល់អគ្គនាយក Javier Montañez
  សារព័ត៌មាន Boston Globe ចុះថ្ងៃទី 13 ខែមេសា ឆ្នាំ 2022
- មន្ត្រីផ្នែកអប់រំ Elorza ប្រារព្ធពិធីបើកការដ្ឋានសាងសង់មជ្ឈមណ្ឌលសិក្សាថ្មីក្នុងក្រុង Providence
  សារព័ត៌មាន ABC 6 ថ្ងៃទី13 ខែមេសា ឆ្នាំ 2022
- ថ្ងៃចុះកម្មសិក្សាក្នុងមហាវិទ្យាល័យនៅ Brown ផ្តល់ឱ្យសិស្សនៅវិទ្យាល័យ Providence នូវទិដ្ឋភាពសង្ខេបនៃជីវិតក្នុងបរិវេណសាលានិងការសិក្សា។
  សារព័ត៌មាន Brown News ថ្ងៃទី 14 ខែមេសា ឆ្នាំ 2022

សម្គាល់ទុកក្នុងប្រតិទិនរបស់អ្នក!

- បុណ្យ EID AL-FITR - សាលាបិទ
  ថ្ងៃអង្គារ ថ្ងៃទី 3 ខែមេសា ឆ្នាំ 2022
- ថ្ងៃនៃការអភិវឌ្ឍវិជ្ជាជីវៈ:
  ថ្ងៃពុធ ទី11 ខែឧសភា ឆ្នាំ 2022
- ទិវានៃកេរ្តិ៍រំលឹក - សាលាបិទ
  ថ្ងៃច័ន្ទ ទី 30 ខែឧសភា ឆ្នាំ 2022
- ពេលកំណត់សម្រាប់ការចុះឈ្មោះក្នុងកម្មវិធីសិក្សាក្នុងរដូវក្តៅ
  ថ្ងៃពុធ ទី 4 ខែមេសា ឆ្នាំ 2022
- ក្រុមប្រឹក្សាយោបល់សម្រាប់ឪពុកម្តាយ
  ថ្ងៃច័ន្ទ ទី16 ខែឧសភា ឆ្នាំ 2022
  ម៉ោង 6:00 p.m.
- ពិព័រណ៍ការងារនៅ PPSD
  ថ្ងៃព្រហស្បតិ៍ទី 5 ខែឧសភា ឆ្នាំ 2022
  ម៉ោង 5:00 p.m. - 7:00 p.m.
- ជំនួបប្រជុំក្រុមប្រឹក្សាសាលា
  ថ្ងៃពុធ ទី 18 ខែឧសភា ឆ្នាំ 2022
  ម៉ោង 6:30 p.m.

ចូរផ្សព្វផ្សាយពាក្យ

Providence Schools
EARLY CHILDHOOD PROGRAM

ពិព័រណ៍ការងារ

PPSD នឹងប្រារព្ធពិព័រណ៍ការងារក្នុងនិទាឃរដូវលើកទីពីរនៅអនុវិទ្យាល័យ DelSesto នៅថ្ងៃទី 5 ខែឧសភា ពីម៉ោង 5-7:00 p.m. ។ បុគ្គលិកខាងក្នុងដែលកំពុងស្វែងរកមុខដំណែងនៅឡើយ នៅក្នុងមណ្ឌលសិក្សាត្រូវបានស្វាគមន៍ និងលើកទឹកចិត្តឱ្យមកចូលរួម។ សូមចុះឈ្មោះ និងទាក់ទងមកកាន់ jacqueline.duarte@ppsd.org ជាមួយនឹងសំណួរណាមួយ។

ការងារយុវជន

ពាក្យស្នើសុំសម្រាប់ឱកាសការងារយុវជនជាមួយនាយកដ្ឋានឧទ្យាន និងទីកម្សាន្តរបស់ទីក្រុងឥឡូវនេះបានបើកហើយ → ស្វែងយល់បន្ថែម៖
http://pvdsummerjobs.com

ថ្នាក់មុនចូលមត្តេយ្យរបស់ PPSD

ឆ្នោតកម្មវិធីថ្នាក់មុនមត្តេយ្យសិក្សារបស់ RI និងថ្នាក់មុនមត្តេយ្យសិក្សាដែលបានបញ្ចូលគ្នាក្នុងឆ្នាំសិក្សា 2022-2023 បានបើកហើយ។ កម្មវិធីទាំងនេះផ្តល់ជូនការអប់រំកម្រិតថ្នាក់មុនចូលមត្តេយ្យសិក្សាប្រកបដោយគុណភាពខ្ពស់ដោយមិនគិតថ្លៃដល់កុមារអាយុ 3, 4 និង 5 ឆ្នាំក្នុងក្រុង Providence ។ ស្វែងយល់ព័ត៌មានបន្ថែមនៅទីនេះ >

រឿងអស្ចារ្យកំពុងកើតឡើងទូទាំងមណ្ឌល ហើយយើងចង់ឱ្យអ្នកបានដឹង! ប្រសិនបើអ្នកមានកម្មវិធី ព្រឹត្តិការណ៍ សមាជិកបុគ្គលិក ឬសិស្សដែលមានរឿងដ៏អស្ចារ្យដែលអ្នកចង់រំលែក សូមផ្ញើអ៊ីមែលទៅ communications@ppsd.org ។

Providence Schools

© សាលារៀនសាធារណៈ Providence 2022· communications@ppsd.org · www.providenceschools.org